# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ ០៦៥ គ.ជ.ប

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## តួនាទី ភារកិច្ច របស់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត មានគោលបំណងកំណត់វិធានសំខាន់ៗ ឱ្យអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍បោះឆ្នោតអនុវត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជំហរអព្យាក្រឹត មិនលម្អៀង ដើម្បីធានាឱ្យ ៖

- កិច្ចសង្កេតការណ៍បោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិតភាព និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោត បំពេញការងារដោយពុំមានការជ្រៀតជ្រែក។

អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល *អាច* បញ្ជូនតំណាងរបស់ខ្លួនឱ្យមកចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត។ ពាក្យថា *អាច* មានន័យថា ចូលរួមក៏បានមិនចូលរួមក៏បាន។ បើទោះបីជាច្បាប់មិនបានចាប់បង្ខំយ៉ាងណាក៏ដោយ គ.ជ.ប នៅតែលើកទឹកចិត្តឱ្យមានអ្នកសង្កេតការណ៍ច្រើន ដើម្បីចូលរួមឃ្លាំមើលសុចរិតភាពការងាររបស់ គ.ជ.ប។

អ្នកសង្កេតការណ៍បោះឆ្នោតនៅពេលដែល គ.ជ.ប បានទទួលស្គាល់ជាផ្លូវការ មានសិទ្ធិ ជាអាទិ៍ ៖

- អ្នកសង្កេតការណ៍ជាតិ អាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ចល័តទូទាំងប្រទេស ដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប ។
- អ្នកសង្កេតការណ៍អន្តរជាតិ អាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

ទន្ទឹមនឹងមានសិទ្ធិ អ្នកសង្កេតការណ៍បោះឆ្នោតក៏មានបម្រាមក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍មិនត្រូវធ្វើ ជាអាទិ៍ ៖

- ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។
- ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។
- ស្នងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

- សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយនៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

យោងតាមមាត្រា ១៩៨ ត្រូវផាកពិន័យជាប្រាក់ពី ១០,០០០,០០០ (ដប់លាន) រៀល ទៅ ២០,០០០,០០០ (ម្ភៃលាន) រៀល ដោយ គ.ជ.ប ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៨៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការទទួលខុសត្រូវនេះ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ដែលបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។ ចំណុច ១ ក្នុងមាត្រា ៨៥ បានចែងថា "*ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀងមានជាអាទិ៍ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ត្រូវបានហាមឃាត់*" ។

គំរូពាក្យសុំចុះឈ្មោះសម្រាប់អ្នកសង្កេតការណ៍ផ្តល់ជូនដោយឥតគិតថ្លៃ ឬអាចទាញយកទម្រង់បែបបទរបស់ខ្លួនពីគេហទំព័ររបស់ គ.ជ.ប www.necelect.org.kh/khmer/content/3064 (អ្នកសង្កេតការណ៍ជាតិ) www.necelect.org.kh/khmer/content/3065 (អ្នកសង្កេតការណ៍អន្តរជាតិ) និងត្រូវដាក់ពាក្យនៅ គ.ជ.ប រៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១១:៣០នាទី ពេលរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០នាទី ។

សូមជម្រាបជូនថា បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយ ត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ផ្ញើជូន គ.ជ.ប ។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 959 666<br>Email : hangputhea@gmail.com | ឯកឧត្តម **ឌីម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 518 485<br>Email : sovannaromhy@yahoo.fr |